ទំនុកដំកើង១១៤-១១៦

# ជំពូក ១១៤

***ខាងចនា*** *ព្រះជាម្ចាស់ដឹកដៃកូនទ្រង់*

ជំពូក១១៤ ជាផ្នែកមួយនៃចង្កោមបទសរសើរពីជំពូក១១៣-១១៨។ បទសរសើរទាំងនេះ ត្រូវប្រើនៅពេលធ្វើបុណ្យរំលង បុណ្យថ្ងៃទីហាសិប បុណ្យបារាំ និងធ្វើបុណ្យឆ្លងសមិទ្ធិអ្វីមួយ។ នៅពេលប្រារព្ធធ្វើបុណ្យរំលង គេច្រើនច្រៀងបីជំពូក នៅពេលចាប់ផ្ដើម ហើយបីជំពូកទៀតនៅពេលចប់ពិធី។ ជួនកាលគេប្រើបទទាំងនោះសម្រាប់ច្រៀងនៅក្នុងអំឡុងពេលធ្វើបុណ្យរំលងទាំងមូលក៏មានដែរ។

ជំពូក១១៤ជាបទសរសើរពីភាពអស្ចារ្យនៃព្រះជាម្ចាស់ ដូចយើងបានឃើញនៅក្នុងជំពូក១១២ និង១១៣រួចមកហើយ។ នៅក្នុងជំពូក១១៣ បទសរសើរសម្ដែងពីព្រះជាម្ចាស់ជាអង្គនិម្មាបនិក ទ្រង់ជាព្រះដ៏ប្រោសលោះ ទាំងមនុស្សលោក ទាំងពិភពលោកទាំងមូល ដែលទ្រង់បានបង្កើតមក។ ជំពូក១១៤ ជាបទចម្រៀងសម្រាប់សរសើរតម្កើងដល់ព្រះជាម្ចាស់ដែរ។

ម្យ៉ាងទៀតសូមកត់ចំណាំថា ជំពូក១១៤រំឭកពីគ្រាដែលព្រះជាម្ចាស់រំដោះសាសន៍អ៊ីស្រាអែល ចេញពីភាពខ្ញុំកំដរនៅប្រទេសអេស៊ីព្ទ។

**កាលសាសន៍អ៊ីស្រាអែល បានចេញពីស្រុកអេស៊ីព្ទ គឺកាលពូជពង្សនៃយ៉ាកុប បានចេញពីសាសន៍ដែលមានភាសាទីទៃ (ទំនុកដំកើង១១៤:១)។**

នៅគ្រាដែលលោកអ័ប្រាហាំ ធ្វើដំណើរចុះមកពីស្រុកខាងជើង មកតាំងទីលំនៅនៅក្នុងទឹកដីសន្យា លោកជាសាសន៍ដទៃសុទ្ធសាធ។ ក្នុងពេលនោះ ព្រះជាម្ចាស់មានបន្ទូលទៅកាន់លោកថា ពូជពង្សរបស់លោក ត្រូវធ្វើដំណើរចុះទៅនៅប្រទេសអេស៊ីព្ទ។ នៅទីនោះ ពូជពង្សរបស់លោក កើតជាកូន ពូនជាចៅរហូតដល់ក្លាយទៅជានគរមួយ។ ប្រវត្តិសាស្ត្រសម្ដែងអោយយើងដឹងថា សាសន៍អ៊ីស្រាអែលកើតជានគរមួយនៅលើទឹកដីអេស៊ីព្ទ។ ឯគំនិតស្អប់ខ្ពើមដល់សាសន៍អ៊ីស្រាអែល ត្រូវចាប់ផ្ដើមពីប្រទេសអេស៊ីព្ទដែរ។ ព្រះគម្ពីរបានសម្ដែងអោយយើងដឹងថា ដោយសារមានការស្អប់ខ្ពើមដល់សាសន៍អ៊ីស្រាអែលនេះហើយ បានជាសាសន៍នេះត្រូវទទួលរងវេទនាយ៉ាងខ្លាំង ទទួលការបៀតបៀនយ៉ាងសាហាវយង់ឃ្នង នៅក្នុងប្រទេសនោះ។ ប៉ុន្តែ ទោះសាសន៍អ៊ីស្រាអែលរងទុក្ខលំបាកយ៉ាងដូច្នោះក៏ដោយ ព្រះជាម្ចាស់នៅតែនឹកឃើញពីសេចក្ដីសន្យា ដែលទ្រង់បានមានបន្ទូលជាមួយនឹងលោកអ័ប្រាហាំ។ ព្រះអង្គស្ដាប់ឮសម្រែករបស់សាសន៍អ៊ីស្រាអែល ព្រមទាំងយាងទៅឯសាសន៍នោះ ដើម្បីរំដោះគេអោយរួចពីទាសកម្មនៅក្នុងប្រទេសអេស៊ីព្ទ។ ហេតុការណ៍ខាងលើ ជាសាវតារដែលនាំអោយគេកត់ត្រាគម្ពីរទំនុកដំកើងជំពូក១១៤នេះមក។

**នោះពួកយូដាបានត្រឡប់ជាទីបរិសុទ្ធរបស់ទ្រង់ ហើយពួកអ៊ីស្រាអែលបានធ្វើជាអាណាខេត្តរបស់ទ្រង់ (ទំនុកដំកើង ១១៤:២)។**

ព្រះជាម្ចាស់ហៅសាសន៍យូដាទាំងមូលថា ជាទីបរិសុទ្ធរបស់ទ្រង់។ កាលដើមដំបូងព្រះជាម្ចាស់ចង់អោយសាសន៍អ៊ីស្រាអែលទាំងមូល ធ្វើជាសង្ឃសម្រាប់ពិភពលោកយើងទាំងមូល។ ក្នុងគ្រាសព្វថ្ងៃ យើងមិនឃើញមានហេតុការណ៍នេះកើតឡើងយ៉ាងដូច្នោះទេ។ ប៉ុន្តែ ក្នុងគ្រាព្រះអម្ចាស់យេស៊ូវយាងមកសោយរាជ្យមួយពាន់ឆ្នាំលើលោកយើងនេះ សាសន៍អ៊ីស្រាអែលបំពេញតួនាទីជាសង្ឃ សម្រាប់មនុស្សលោកលើសកលលោកទាំងមូល។

**សមុទ្របានឃើញ ហើយក៏រត់បាត់ទៅ ទន្លេយ័រដាន់ក៏ហូរថយក្រោយវិញ (ទំនុកដំកើង១១៤:៣)។**

ក្រោយចាកចេញពីប្រទេសអេស៊ីព្ទ សាសន៍អ៊ីស្រាអែលឆ្លងសមុទ្រក្រហម និងឆ្លងទន្លេយ័រដាន់ (យ៉ូស្វេ៣:១៣-១៧)។

**ឱសមុទ្រអើយ តើវាថ្វី បានជារត់ទៅដូច្នេះ ហើយទន្លេយ័រដាន់**

**ឯងដែរ បានជាហូរថយប្រាសទៅ (ទំនុកដំកើង ១១៤:៥)។**

ព្រះជាម្ចាស់ទ្រង់ជាអង្គនិម្មាបនិក។ ព្រះអង្គជាព្រះប្រកបដោយសព្វានុភាព។ ព្រះអង្គមានចេស្តាអាចញែកសមុទ្រក្រហមជាពីរ ធ្វើជាផ្លូវគោកសម្រាប់សាសន៍ទ្រង់អាចដើរឆ្លងកាត់បាន។ ក្រោយមកទៀតព្រះអង្គបានទប់ទឹកទន្លេយ័រដាន់ កំពុងជន់ពេញច្រាំងមិនអោយហូរ ទុកអោយសាសន៍អ៊ីស្រាអែលមានដីគោក សម្រាប់ឆ្លងទន្លេយ័រដាន់ដើរឆ្ពោះទៅកាន់ទឹកដីសន្យា។ ហេតុការណ៍ទាំងពីរដូចបានរៀបរាប់ខាងលើជាហេតុការណ៍ដ៏អស្ចារ្យ។ ព្រះជាម្ចាស់បានធ្វើសម្រាប់រាស្ត្ររបស់ទ្រង់។ ការឆ្លងសមុទ្រ ឆ្លងទន្លេ មានអត្ថន័យខ្លឹមសារយ៉ាងជ្រាលជ្រៅខាងព្រលឹងវិញ្ញាណ។ ពេលសាសន៍អ៊ីស្រាអែលឆ្លងសមុទ្រក្រហម គេឆ្លងដោយពឹងពាក់លើឈាមដែលព្រះជាម្ចាស់បង្គាប់អោយសាសន៍អ៊ីស្រាអែលគ្រប់ៗគ្នា លាបនៅលើក្របទ្វារផ្ទះរៀងខ្លួន។ ចំណែកនៅពេលសាសន៍អ៊ីស្រាអែលឆ្លងកាត់ទន្លេយ័រដាន់ គេធ្វើដំណើរឆ្លងពីទីរហោស្ថាន ចូលមកទឹកដីសន្យា។

បទពិសោធន៍ខាងលើ ទាក់ទងនឹងសេចក្តីសង្គ្រោះដល់ព្រលឹងរបស់មនុស្សមានបាបគ្រប់រូបដែរ។ សេចក្តីប្រោសលោះមានពីរដំណាក់។ ទីមួយ ព្រះអម្ចាស់យេស៊ូវសុគតនៅលើឈើឆ្កាង ដើម្បីលោះយើងពីពិរុទ្ធភាពនៃអំពើបាប ដែលយើងបានប្រព្រឹត្តកន្លងទៅ។ បន្ទាប់ពីព្រះអង្គបានប្រោសលោះយើងហើយ ព្រះអង្គបន្តរំដោះយើងអោយរួចពីឥទ្ធិពលនៃអំពើបាបដែលយើងតែងធ្លាក់ខ្លួនប្រព្រឹត្តជារៀងរាល់ថ្ងៃ។ មិនតែប៉ុណ្ណោះ

ព្រះអម្ចាស់យេស៊ូវទ្រង់នឹងរំដោះយើង អោយរួចពីអំពើបាបណាមួយ ដែលយើងមិនទាន់គិតឃើញថា នឹងបានធ្វើក្នុងគ្រាអនាគតថែមទៀតផង។ ដូច្នេះ បទពិសោធន៍នៃការធ្វើដំណើរឆ្លងកាត់សមុទ្រក្រហម និងការឆ្លងកាត់ទន្លេយ័រដាន់ ជារូបភាពនៃការប្រោសលោះពីរដំណាក់កាល។

> **៧ឱផែនដីអើយ ចូរញ័ររន្ធត់នៅចំពោះព្រះអម្ចាស់ គឺនៅចំពោះ**
> **ព្រះនៃយ៉ាកុបចុះ ៨ជាព្រះដែលធ្វើឱ្យថ្មដាប្រែទៅជាត្រពាំងទឹក គឺ**
> **ថ្មរឹងឱ្យទៅជាក្បាលទឹកហូរ (ទំនុកដំកើង ១១៤:៧-៨)។**

បច្ចុប្បន្ន យើងហៅបុណ្យរំលងថា ជាពិធីលៀងព្រះអម្ចាស់។ ពិធីលៀងព្រះអម្ចាស់ រំឭកពីព្រះគុណរបស់ព្រះជាម្ចាស់ និងចេស្ដារបស់ទ្រង់ក្នុងការប្រោសលោះ ហើយថែរក្សារាស្ដ្ររបស់ព្រះអង្គគ្រប់ៗរូប។

# ជំពូក ១១៥

**ឆាចចនា** *ព្រះជាម្ចាស់ខុសពីរូបព្រះ*

ព្រះអម្ចាស់យេស៊ូវច្រៀងទំនុកដំកើងជំពូក១១៥ ពេលទ្រង់គង់យប់ចុងក្រោយ បង្អស់ជាមួយពួកសិស្សរបស់ទ្រង់នៅបន្ទប់ខាងលើ។ នៅយប់នោះឯង ព្រះអង្គបាន បង្កើតអោយមានពិធីមួយហៅថា ពិធីលៀងព្រះអម្ចាស់។

យើងមិនបានដឹងថា អ្នកកត់ត្រាជំពូក១១៥ជានរណាទេ។ បើតាមសំនួន វោហារ និងពាក្យពេចន៍ក្នុងភាសាហេព្រើរ យើងសន្និដ្ឋានថា អ្នកកត់ត្រាគម្ពីរទំនុក ដំកើងជំពូក១១៥ ជាពួកសាសន៍អ៊ីស្រាអែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសបាប៊ីឡូន។ យើងអាចចែកជំពូក១១៥ ជាបីផ្នែក។ ទីមួយ ចម្រៀងរបស់ក្រុមជំនុំ (ខ១-៨)។ ទីពីរ ចម្រៀងរបស់សង្ឃលេវី (ខ៩-១១)។ និងទីបី ចម្រៀងរបស់ក្រុមជំនុំ (ខ១២-១៨)។

**មិនមែនយើងខ្ញុំ ឱព្រះយេហូវ៉ាអើយ មិនមែនយើងខ្ញុំដែលគួរ លើកដំកើងទេ សូមទ្រង់លើកដំកើងព្រះនាមនៃទ្រង់វិញ ដោយ យល់ដល់សេចក្តីសប្បុរស នឹងសេចក្តីពិតត្រង់របស់ទ្រង់ (ទំនុក ដំកើង ១១៥:១)។**

កន្លងមក សាសន៍អ៊ីស្រាអែលបានធ្វើការបះបោរជាច្រើន ទាស់នឹងព្រះជាម្ចាស់។ ប៉ុន្តែ ពេលគេកត់ត្រាទុកគម្ពីរទំនុកដំកើងជំពូក១១៥ គេសម្តែងទឹកចិត្តថា គេទុកចិត្តដល់ព្រះអង្គខ្លាំងណាស់។ ជំពូកនេះ ជាបទទំនាយទាក់ទងនឹងសាសន៍អ៊ីស្រាអែលសេសសល់ ត្រូវរស់ឆ្លងកាត់គ្រាមហាទុក្ខ។ នៅពេលគ្រាមហាទុក្ខឈានមកដល់ទីបញ្ចប់ រាជ្យសហស្សវត្សរ៍ក៏ចូលមកដល់។ ពេលនោះសាសន៍អ៊ីស្រាអែលមានទឹកចិត្តគោរពកោតខ្លាចដល់ព្រះជាម្ចាស់។ ដូច្នេះហើយ បានជាក្នុងប្រពៃណីទំនៀមទម្លាប់របស់សាសន៍អ៊ីស្រាអែល គេច្រៀងទំនុកដំកើងជំពូក១១៥ ពេលគេប្រារព្ធធ្វើពិធីបុណ្យរំលង ពិធីបុណ្យថ្ងៃទីហាសិប និងពិធីបុណ្យបារាំ។

នៅពេលសាសន៍អ៊ីស្រាអែលជួបគ្រាមហាទុក្ខ សាសន៍ដទៃនាំគ្នាពោលប្រមាថដល់សាសន៍អ៊ីស្រាអែលថា "តើព្រះឯងនៅឯណា?"

**តើមានទំនងអ្វីឱ្យពួកសាសន៍ដទៃសួរថា តើព្រះគេនៅឯណា (ទំនុកដំកើង១១៥:២)។**

សព្វថ្ងៃមានគេដៀលយើងថា "ឯងចេះតែអួតថា ព្រះរបស់ឯងគង់នៅ ហេតុអ្វីបានជាព្រះរបស់ឯងមិនមកជួយឯងក្នុងពេលនេះផងទៅ?"

**ចំណែកព្រះនៃយើងខ្ញុំ ទ្រង់គង់នៅស្ថានសួគ៌ ទ្រង់បានធ្វើការ**

**ដែលគាប់ដល់ព្រះហឫទ័យទ្រង់ហើយ (ទំនុកដំកើង១១៥:៣)។**

ព្រះជាម្ចាស់បណ្តោយ អោយសាសន៍អ៊ីស្រាអែលឆ្លងកាត់ទុក្ខលំបាក ពីព្រោះគេបានប្រព្រឹត្តអំពើបាប។ បទពិសោធន៍ដែលសាសន៍អ៊ីស្រាអែលកំពុងឆ្លងកាត់ ស្ថិតនៅក្នុងគម្រោងការណ៍ និងវត្ថុបំណងរបស់ព្រះជាម្ចាស់។ ពេលដែលសាសន៍អ៊ីស្រាអែលជួបទុក្ខលំបាក គេចាប់ផ្តើមទទួលស្គាល់ថា គេបានប្រព្រឹត្តអំពើទាស់ជាមួយនឹងព្រះជាម្ចាស់ ជាព្រះរបស់គេមែន។

ពេលគេឃ្លាតចាកឆ្ងាយពីព្រះជាម្ចាស់ សាសន៍អ៊ីស្រាអែលធ្លាប់ថ្វាយបង្គំរូបព្រះ។ លុះគេជួបទុក្ខលំបាក គេឃើញរូបព្រះហាក់គ្មានន័យអ្វីបន្តិចសម្រាប់គេទាល់តែសោះ។ ដូច្នេះបានជាគេរៀបរាប់ពីរូបព្រះដូចខាងក្រោមនេះថា:

**ឯព្រះរបស់គេ នោះសុទ្ធតែជារូប ធ្វើពីប្រាក់នឹងមាស ជាស្នាដៃដែលមនុស្សធ្វើ (ទំនុកដំកើង១១៥:៤)។**

បើប្រៀបធៀបទៅនឹងរូបព្រះ ព្រះជាម្ចាស់ជាព្រះដែលគង់នៅស្ថានសួគ៌ និងជាអង្គនិម្មាបនិក។ ទ្រង់ជាវិញ្ញាណ។ មនុស្សមិនអាចបង្កើតព្រះអង្គបានទេ។ ចំណែកឯរូបព្រះវិញ មនុស្សអាចយកមាស យកប្រាក់ យកឈើ យកដី យកថ្ម មកសូនធ្វើបាន។ បើមនុស្សមានគំនិតថា ព្រះមានទ្រង់ទ្រាយបែបណា គេនឹងសូនព្រះរបស់គេអោយ

ដូចរូបដែលគេចង់បាន។ មនុស្សមិនអាចធ្វើព្រះជាម្ចាស់បានជាដាច់ខាត។ ព្រះជាម្ចាស់អាចធ្វើមនុស្សកើត។

> **៥ រូបទាំងនោះមានមាត់ តែមិនចេះនិយាយ មានភ្នែក តែមើលមិនឃើញ ៦ មានត្រចៀក តែស្ដាប់មិនឮ មានច្រមុះ តែធុំក្លិនមិនបាន (ទំនុកដំកើង១១៥:៥-៦)។**

រូបព្រះមានភ្នែក មានច្រមុះ មានត្រចៀក មានមាត់ មានដៃ មានជើងជាដើម។ ប៉ុន្តែ រូបព្រះមិនអាចប្រើអវយវៈដែលមនុស្សបានធ្វើអោយខ្លួនកើតឡើយ។

> **មានដៃ តែចាប់កាន់មិនបាន មានជើង តែមិនចេះដើរឡើយ ក៏មិនចេះបញ្ចេញសំឡេងតាមបំពង់កផង (ទំនុកដំកើង១១៥:៧)។**

ម្យ៉ាងទៀត រូបព្រះមិនអាចជួយខ្លួនឯងបាន។ គម្ពីរអេសាយ៤៤:១៤-១៧ ថែងពីរូបព្រះថា "គាត់កាប់ដើមតាត្រៅ១ ក៏យកដើមចន្ទន៍ ក្រឹស្នា នឹងដើមម៉ៃសាក់ គឺគាត់រើសយកតែឈើណាដែលជាប់ៗនៅក្នុងព្រៃ ឬគាត់ដាំដើមខ្ទាវដែលដុះលាស់ឡើង ដោយសារទឹកភ្លៀង ទាំងអស់នេះមានប្រយោជន៍ដល់មនុស្សសំរាប់ធ្វើឧសដុត គេក៏យកខ្លះមកដុតអាំង អើ ក៏យកខ្លះបង្កាត់ភ្លើងដុតនំបុ័ង អើ ក៏ធ្វើព្រះ១ឡើង រួចក្រាប

ថ្វាយបង្គំ គឺគាត់ឆ្លាក់ធ្វើជារូប ហើយក្រាបចុះគោរពដល់រូបនោះ ដូច្នេះ គាត់យកខ្លះធ្វើឧសដុត ខ្លះទៀតដុតធ្វើម្ហូប គឺគាត់អាំងសាច់ ហើយស៊ីឆ្អែត អើ គាត់កំដៅខ្លួនដែរ ដោយពោលថា អែយ៉ា ក្តៅស្រួលហ្ន៎ ខ្ញុំអាំងភ្លើងហើយ ឯឈើដែលសល់ នោះគាត់យកទៅធ្វើជារូបឆ្លាក់សំរាប់ខ្លួន ក៏ក្រាបចុះថ្វាយបង្គំ ហើយអធិស្ឋានដល់រូបនោះដោយពាក្យថា សូមជួយសង្គ្រោះខ្ញុំផង ពីព្រោះលោកជាព្រះនៃខ្ញុំ”។ ពេលសិតធ្វើរូបព្រះបានល្អហើយ គេត្រូវរកមធ្យោបាយ ដើម្បីដឹកជញ្ជូនរូបព្រះទៅដល់កន្លែងដែលគេអភិសេកធ្វើជាព្រះរបស់គេ។ រូបព្រះធុនតូច គេព្យួរនឹងករបស់គេ។ រូបព្រះធុនធំល្មម គេលីនៅលើស្មា។ ឯរូបព្រះធំហួសកម្លាំងគេលើក គេដឹកនឹងរទេះគេ រទេះសេះ ដាក់ឡានដើម្បីដឹកទៅដល់កន្លែងដែលគេតាំងរូបនោះថា ជាព្រះរបស់គេ។ តើលោកអ្នកឃើញហើយឬនៅថា រូបព្រះខុសពីព្រះជាម្ចាស់។ មនុស្សត្រូវលីសែងរូបព្រះដែលខ្លួនបានសិតរួចហើយ។ ចំណែកព្រះជាម្ចាស់នៃស្ថានសួគ៌វិញ ទ្រង់មានបន្ទូលថា “អញជាព្រះយេហូវ៉ា គឺជាព្រះដែលបានបីទ្រឯង ចាប់តាំងពីឯងនៅក្នុងផ្ទៃម្តាយមក”។ តើព្រះរបស់លោកអ្នកបីទ្រលោកអ្នក ឬក៏លោកអ្នកបីទ្រព្រះរបស់លោកអ្នក? បើលោកអ្នកបីទ្ររូបព្រះរបស់លោកអ្នក រូបព្រះនោះជាបន្ទុកសម្រាប់លោកអ្នកហើយ។ រូបព្រះរបស់លោកអ្នកមិនបានជួយបន្ធូរបន្ថយទុក្ខលំបាករបស់លោកអ្នកទេ។ មួយថ្ងៃៗគេបន្ថែមទុក្ខលំបាកដល់លោកអ្នក បើលោកអ្នកធ្វើខុសអ្វីមួយនឹងរូបព្រះដែលលោកអ្នកបានអភិសេកឡើង។ ចំណែកព្រះជាម្ចាស់វិញ ទ្រង់តែងបីទ្រលោកអ្នក។ ពេលលោកអ្នកមានទុក្ខលំបាកព្រះអង្គជួយដល់លោកអ្នកផ្ទាល់។ ផ្ទុយទៅវិញ បើលោកអ្នកជឿលើព្រះជាម្ចាស់ហើយ

បែរជាចង់បីទ្រទ្រង់វិញ ទោះបីលោកអ្នកជាគ្រីស្ទបរិស័ទក៏ដោយ លោកអ្នកកំពុងថ្វាយបង្គំរូបព្រះមួយទៀត ដែលមានលក្ខណៈដូចព្រះជាម្ចាស់។ សូមលោកអ្នកកុំប្រៀបធៀបព្រះជាម្ចាស់អោយស្មើនឹងរូបព្រះអោយសោះ។ ព្រះនិងរូបព្រះខុសគ្នាដូចមេឃនិងដី។

នៅពេលខ្មាំងសត្រូវបានមើលងាយដល់រាស្ត្ររបស់ព្រះជាម្ចាស់ ពួកសង្ឃលេវី មានចម្លើយសម្រាប់ឆ្លើយតបទៅកាន់អ្នកដែលគេមើលងាយដល់ខ្លួនថា:

**៩ឱអ៊ីស្រាអែលអើយ ចូរទុកចិត្តនឹងព្រះយេហូវ៉ាចុះ ទ្រង់ជាអ្នក**
**ជួយ នឹងជាខែលរបស់ឯង ១០ឱពួកវង្សអើរ៉ុនអើយ ចូរទុកចិត្តនឹង**
**ព្រះយេហូវ៉ាចុះ ទ្រង់ជាអ្នកជួយ នឹងជាខែលរបស់ឯង ១១ឱពួកអ្នក**
**ដែលកោតខ្លាចដល់ព្រះយេហូវ៉ាអើយ ចូរទុកចិត្តនឹងព្រះយេហូវ៉ាចុះ ទ្រង់ជាអ្នកជួយ នឹងជាខែលរបស់ឯង (ទំនុកដំកើង ១១៥:៩-១១)។**

សព្វថ្ងៃមានអំពើកើតឡើងយ៉ាងជោរជន់នៅក្នុងសង្គមមនុស្ស។ តែងសួរថា "តើត្រូវដោះស្រាយវិបត្តិនៅក្នុងសង្គមដោយវិធីណា?" រឿងបង្កើតកម្មវិធីដោះស្រាយអំពើអសីលធម៌ ជារឿងត្រឹមត្រូវតាមទិសដៅដែលត្រូវធ្វើហើយ។ ប៉ុន្តែ បើនាំគ្នាដោះស្រាយវិបត្តិសីលធម៌ចុះឱនថយ ដោយប្រើកម្លាំងបាយ បញ្ហានោះមិនអាចដោះស្រាយបានទេ ពីព្រោះដើម្បីបានកម្លាំងបាយ មនុស្សត្រូវប្រព្រឹត្តអំពើអសីលធម៌ទើបបានបាយ

ទទួលទាន។ ធ្វើដូចម្តេចដើម្បីដោះស្រាយបញ្ហានោះអោយមានប្រសិទ្ធភាព? ចម្លើយមានបង្កប់នៅក្នុងខខាងលើ "ត្រូវទុកចិត្តដល់ព្រះជាម្ចាស់ អោយអស់ពីព្រលឹងរបស់ខ្លួន"។ ជំនឿលើព្រះជាម្ចាស់ មិនមែនគ្រាន់តែនិយាយត្រឹមបបូរមាត់តែប៉ុណ្ណោះទេ។ ចិត្ត និងការប្រព្រឹត្តរបស់យើង ត្រូវអនុវត្តកិរិយាបរិសុទ្ធតាមព្រះបន្ទូលរបស់ព្រះអង្គ ទើបរាប់ថា ជាជំនឿមានតម្លៃ។ សូមទុកចិត្តលើព្រះជាម្ចាស់ ព្រមទាំងដើរយ៉ាងកៀកកិតជាមួយនឹងព្រះអង្គជារៀងរាល់ថ្ងៃ។ សូមផ្ទេរអស់ទាំងបន្ទុករបស់លោកអ្នកទៅលើព្រះអង្គចុះ។ ខគម្ពីរខាងលើ ជាការអំពាវនាវ សូមអោយយើងរស់នៅដោយមានប្រកបជាមួយនឹងទ្រង់យ៉ាងជិតស្និទ្ធជារៀងរាល់ថ្ងៃ។

ឥឡូវនេះ យើងឈានមកដល់ខ១២ ដែលពួកជំនុំត្រូវច្រៀងរួមគ្នា។

**ព្រះយេហូវ៉ាទ្រង់បាននឹកចាំពីយើងខ្ញុំ ទ្រង់នឹងប្រទានពរពិត ទ្រង់នឹងប្រទានពរដល់ពួកវង្សអ៊ីស្រាអែល ទ្រង់នឹងប្រទានពរដល់ពួកវង្សអើរ៉ុន (ទំនុកដំកើង១១៥:១២)។**

ព្រះជាម្ចាស់ប្រទានពរដល់សាសន៍អ៊ីស្រាអែល និងដល់យើងរាល់គ្នាដែរ។ ព្រះអម្ចាស់ប្រទានពរដល់មិត្តភក្តិ ដល់លំនៅស្ថាន ដល់ក្រុមជំនុំ ដល់នគររបស់លោកអ្នក បើលោកអ្នកព្រមបែរមករកព្រះអង្គ។ ព្រះជាម្ចាស់មិនដែលភ្លេចយើងទេ។ ព្រះអង្គស្គាល់លោកអ្នកទាំងឈ្មោះ ទាំងអស័យដ្ឋានរបស់លោកអ្នក។ នៅពេលខ្ញុំធ្វើដំណើរ

តាមអាកាសយាន ខ្ញុំមើលពីលើអាកាសមកឃើញទីក្រុងនីមួយៗ មានផ្ទះយ៉ាងណែនណាន់តាន់តាប់។ ខ្ញុំមិនដឹងថា អ្នកណានៅផ្ទះណាទេ។ ប៉ុន្តែ ព្រះជាម្ចាស់វិញ ទ្រង់ស្គាល់ផ្ទះណា ជារបស់អ្នកណា អស័យដ្ឋានលេខប៉ុន្មាន នៅលើផ្លូវណាមួយ។ លោកអ្នកជាបុគ្គលមួយរូបរស់នៅក្នុងសង្គមមនុស្ស។ លោកអ្នកជាបុគ្គលម្នាក់ ដែលគេរាប់បញ្ចូលថា ជាប្រជាពលរដ្ឋរបស់ពិភពលោកដែលយើងរស់នៅ។ ខ្ញុំមិនស្គាល់លោកអ្នកទេ ប៉ុន្តែព្រះជាម្ចាស់ស្គាល់លោកអ្នកទាំងឈ្មោះ ទាំងទីកន្លែងដែលលោកអ្នករស់នៅ អាយុរបស់លោកអ្នកប៉ុន្មាន ភេទរបស់លោកអ្នក ឯចំនួនសក់ដែលដុះនៅលើក្បាលរបស់លោកអ្នក ព្រះអង្គជ្រាបថា មានចំនួនប៉ុន្មានសរសៃ។ ព្រះជាម្ចាស់ស្គាល់លោកអ្នក សូមទុកចិត្តដល់ព្រះអង្គចុះ។

**ទ្រង់នឹងប្រទានពរដល់អស់អ្នក ទាំងតូចទាំងធំ ដែលកោតខ្លាចព្រះយេហូវ៉ា (ទំនុកដំកើង១១៥:១៣)។**

ព្រះបន្ទូលក្នុងខខាងលើ ច្បាស់លាស់ជាងពន្លឺថ្ងៃទៅទៀត។ លោកអ្នកអាចជ្រើសរើសជឿលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដែលសម្តែងនៅក្នុងខខាងលើ ឬមួយលោកអ្នកបដិសេធន៍មិនព្រមជឿក៏បាន។ បើលោកអ្នកព្រមជឿស្ថានភាពនៅក្នុងជីវិតរបស់លោកអ្នក ពិតជាមានការខុសប្លែក។

**[១៤] ព្រះយេហូវ៉ាចំរើនឯងរាល់គ្នា ឱ្យកាន់តែច្រើនឡើង គឺឯងរាល់គ្នា ហើយនឹងកូនចៅរបស់ឯងរាល់គ្នាផង [១៥] ឯងរាល់គ្នាបានពរពីព្រះយេហូវ៉ា ជាព្រះដែលបានបង្កើតផ្ទៃមេឃ នឹងផែនដី (ទំនុកដំកើង១១៥:១៤-១៥)។**

ព្រះអង្គបញ្ជាក់ថា ទ្រង់ជាអង្គនិម្មាបនិក គឺជាអង្គដែលបង្កើតអ្វីសព្វសារពើដែលមាននៅជុំវិញខ្លួនយើងនៅលើលោកសន្និវាសយើងនេះ។

**ឯស្ថានសួគ៌ គឺជាស្ថានរបស់ព្រះយេហូវ៉ា ចំណែកផែនដីវិញ នោះទ្រង់បានប្រគល់ដល់មនុស្សជាតិ (ទំនុកដំកើង១១៥:១៦)។**

ព្រះជាម្ចាស់ចែកឋានសម្រាប់មនុស្សរស់នៅ។ មនុស្សមិនត្រូវរស់នៅលើឋានព្រះចន្ទទេ។ ព្រះអង្គចែកឋានផែនដីនេះ សម្រាប់អោយមនុស្សលោក។

**មនុស្សស្លាប់រមែងមិនសរសើរដល់ព្រះយេហូវ៉ាទេ ព្រមទាំងមនុស្សដែលចុះទៅនៅឯស្ថានស្ងាត់ឈឹងផង (ទំនុកដំកើង១១៥:១៧)។**

នៅពេលយើងកំពុងតែរស់នៅលើផែនដីនេះ យើងត្រូវសរសើរដល់ព្រះនាមព្រះយេហូវ៉ា។

**តែចំណែកយើងខ្ញុំ នឹងសូមឱ្យព្រះយេហូវ៉ាបានប្រកបដោយព្រះពរ ចាប់តាំងពីឥឡូវនេះ ដរាបដល់អស់កល្បតទៅ ចូរសរសើរដល់ព្រះយេហូវ៉ាចុះ (ទំនុកដំកើង១១៥:១៨)។**

មនុស្សដែលស្គាល់ព្រះអង្គ ចាប់ផ្តើមថ្វាយពាក្យសរសើរដល់ព្រះយេហូវ៉ា ចាប់តាំងពីជីវិតបច្ចុប្បន្ននេះ រហូតដល់ជីវិតក្នុងបរលោកនាយ។ គេថ្វាយពាក្យសរសើរអស់កល្បជានិច្ចតរៀងទៅ។ ចូរសរសើរដល់ព្រះយេហូវ៉ា ចូរថ្វាយពាក្យហាលេលូយ៉ាដល់ព្រះអង្គ។ តើលោកអ្នកអាចថ្វាយពាក្យសរសើរដល់ព្រះជាម្ចាស់បានដែរឬទេ? បើលោកអ្នកសរសើរដល់ព្រះជាម្ចាស់ លោកអ្នកមិនខុសគ្រូដើមទេ! ផ្ទុយទៅវិញ ឱសថដែលមានប្រសិទ្ធភាពជាទីបំផុតសម្រាប់ចិត្តលោកអ្នកគឺ លោកអ្នកត្រូវចេះថ្វាយការសរសើរដល់ព្រះជាម្ចាស់។ សូមលោកអ្នកចាប់ផ្តើមធ្វើការសន្ទនាជាមួយព្រះអង្គ ពីព្រោះការអធិស្ឋានស្វែងរកព្រះភក្ត្រទ្រង់ ជាឱសថទិព្វសម្រាប់ព្យាបាលជម្ងឺផ្លូវចិត្ត ក៏ដូចជាជម្ងឺរូបកាយរបស់លោកអ្នកបានដែរ។

# ជំពូក ១១៦

*ឆាចចនា សេចក្ដីស្លាប់យកឈ្នះលើព្រះអម្ចាស់មិនបាន*

ជំពូក១១៦ ជាគម្ពីរទំនុកដំកើងថ្វាយពាក្យអរព្រះគុណ។ ជំពូកនេះ ជាបទសរសើរថ្វាយដល់ព្រះជាម្ចាស់។ នៅវេលាយប់មុននឹងគេយកទ្រង់ទៅធ្វើគុតដោយឆ្កាង ព្រះអម្ចាស់យេស៊ូវច្រៀងគម្ពីរទំនុកដំកើងជំពូក១១៦។ ព្រះអង្គច្រៀងបទនេះ ពីព្រោះព្រះអង្គមានព្រះហឫទ័យស្ម័គ្រស្មោះ យាងទៅសុគតនៅលើឈើឆ្កាង ព្រោះទ្រង់ស្រឡាញ់ដល់មនុស្សលោក។ គម្ពីរហេព្រើរ១២:២សម្ដែងថា "ទាំងរំពឹងមើលដល់ព្រះយេស៊ូវដ៏ជាមេផ្ដើម ហើយជាមេសំរេចសេចក្ដីជំនឿរបស់យើង ដែលទ្រង់បានរងទ្រាំនៅឈើឆ្កាង ទាំងមើលងាយចំពោះសេចក្ដីអាមាស់ខ្មាសនោះ ឱ្យតែបានសេចក្ដីអំណរដែលនៅចំពោះទ្រង់ រួចទ្រង់ក៏គង់ខាងស្ដាំបល្ល័ង្កនៃព្រះ"។

ម្យ៉ាងទៀត ជំពូក១១៦សម្ដែងពីហេតុការណ៍ដែលកើតឡើងដល់សាសន៍អ៊ីស្រាអែល ក្នុងគ្រាអនាគត។ នៅពេលសាសន៍អ៊ីស្រាអែលសេសសល់រស់ឆ្លងកាត់គ្រាមហាទុក្ខ គេបានឃើញព្រះអម្ចាស់យេស៊ូវយាងមករំដោះគេ អោយរួចពីទុក្ខដែលគេកំពុងតែឆ្លងនោះ។ ជំពូក១១៦ ជាទំនុកសម្រាប់ពួកអ្នកជឿព្រះអង្គរស់នៅក្នុងសម័យនេះដែរ។ ព្រះជាម្ចាស់មានព្រះហឫទ័យចង់អោយយើងដឹងថា ព្រះអង្គមានសេចក្ដី

សប្បុរស និងសេចក្ដីមេត្តាករុណាចំពោះមនុស្សលោកទាំងឡាយណា ដែលមានទុក្ខលំបាក។ សូមទុកចិត្តដល់ព្រះជាម្ចាស់ចុះ នៅពេលដែលលោកអ្នកមានទុក្ខលំបាក សូមចូលទៅចំពោះព្រះអង្គ ដ្បិតទ្រង់មានព្រះហឫទ័យស្រឡាញ់ដល់លោកអ្នកគ្រប់ៗរូប។

ជំពូក១១៦ចែកជាបីផ្នែកគឺ ខ១-៥ សម្ដែងពីព្រះជាម្ចាស់ទ្រង់ព្រះសណ្ដាប់។ ខ៦-១៣ សម្ដែងពីចេស្ដារបស់ព្រះជាម្ចាស់ ជួយដល់អ្នកដែលហៅរកទ្រង់។ ចំណែក ខ១៤-១៩វិញ សម្ដែងពីព្រះជាម្ចាស់ ថាទ្រង់ជាព្រះដ៏បរិសុទ្ធ។

## ព្រះជាម្ចាស់ទ្រង់ព្រះសណ្ដាប់

**ខ្ញុំស្រឡាញ់ព្រះយេហូវ៉ា ដ្បិតទ្រង់តែងស្ដាប់សំឡេងខ្ញុំ នឹងពាក្យដែលខ្ញុំទូលអង្វរ (ទំនុកដំកើង១១៦:១)។**

ព្រះជាម្ចាស់ស្រឡាញ់ដល់យើងខ្លាំងណាស់។ ព្រះអម្ចាស់សម្ដែងសេចក្ដីស្រឡាញ់របស់ទ្រង់ ដោយយាងមកសុគតជំនួសអំពើបាបរបស់យើងនៅលើឈើឆ្កាង។ ព្រះអង្គស្រឡាញ់ដល់លោកអ្នកណាស់ តើលោកអ្នកស្រឡាញ់ដល់ព្រះអង្គដែរឬទេ? តើលោកអ្នកបានអធិស្ឋានស្វែងរកព្រះភក្ត្រទ្រង់រៀងរាល់ថ្ងៃដែរឬទេ? ម្យ៉ាងទៀត ព្រះអង្គសម្ដែងសេចក្ដីស្រឡាញ់របស់ទ្រង់ចំពោះយើង ដោយព្រះអង្គស្ដាប់សម្លេងដែលយើងអធិស្ឋាន។ ជឿចុះថា ព្រះអង្គស្ដាប់សម្លេងដែលយើងអំពាវនាវហៅរកទ្រង់។

**ចំណងនៃសេចក្ដីស្លាប់បានរុំព័ទ្ធខ្ញុំ ហើយសេចក្ដីឈឺចាប់នៃស្ថានឃុំព្រលឹងមនុស្សស្លាប់បានចាប់ខ្ញុំ ខ្ញុំក៏កើតមានទុក្ខវេទនា នឹងព្រួយបារម្ភ (ទំនុកដំកើង១១៦:៣)។**

នៅលើឈើឆ្កាង ព្រះអម្ចាស់យេស៊ូវរងទុក្ខយ៉ាងខ្លាំង។ ប៉ុន្តែ ព្រះអង្គព្រមទទួលរងទុក្ខដោយស្ម័គ្រព្រះហឫទ័យ ពីព្រោះព្រះអង្គស្រឡាញ់ដល់មនុស្សលោក។ មែនហើយតាមភ្នែករបស់មនុស្ស យើងឃើញព្រះអង្គសុគត តែចំពោះព្រះអង្គវិញ ឥតមានអ្នកណាម្នាក់ អាចដកយកជីវិតពីទ្រង់បានទាល់តែសោះ។

**នោះខ្ញុំបានអំពាវនាវដល់ព្រះនាមព្រះយេហូវ៉ាថា ឱព្រះយេហូវ៉ាអើយ ទូលបង្គំសូមអង្វរដល់ទ្រង់ សូមប្រោសព្រលឹងទូលបង្គំឱ្យរួចផង (ទំនុកដំកើង១១៦:៤)។**

ព្រះជាម្ចាស់ ស្ដាប់សម្លេងដែលព្រះអម្ចាស់យេស៊ូវ អធិស្ឋានអំពាវនាវដល់ព្រះអង្គ។

**ព្រះយេហូវ៉ា ទ្រង់ប្រកបដោយសេចក្ដីមេត្តាករុណានឹងសេចក្ដី**

**សុចរិត អើ ព្រះនៃយើងខ្ញុំ ទ្រង់មានសេចក្តីអាណិតអាសូរ (ទំនុកដំកើង១១៦:៥)។**

ព្រះអង្គស្រឡាញ់ដល់មនុស្សលោក តែព្រះអង្គមានភាពយុត្តិធម៌ ដើម្បីសង្គ្រោះមនុស្សលោក។ ព្រះអង្គត្រូវបញ្ជូនព្រះយេស៊ូវគ្រីស្ទ អោយមកសុគតជំនួសអំពើបាបរបស់មនុស្សលោក ទើបមានភាពយុត្តិធម៌។ ព្រះយេស៊ូវជាផ្លូវ សម្រាប់អោយមនុស្សលោកដើរឆ្ពោះទៅឯព្រះវរបិតា។

## ព្រះទ្រង់សម្តែងព្រះចេស្តាសម្រាប់ជួយ

**៦ ព្រះយេហូវ៉ាទ្រង់ជួយទំនុកបំរុងមនុស្សឆោតល្ងង់ ឯខ្ញុំក៏បានត្រូវ
គេបន្ទាបបន្ថោកម្តង ហើយទ្រង់បានជួយសង្គ្រោះខ្ញុំ ៧ ឱព្រលឹងខ្ញុំ
អើយ ចូរត្រឡប់ទៅឯទីសំរាករបស់ខ្លួនវិញ ដ្បិតព្រះយេហូវ៉ា
ទ្រង់បានប្រព្រឹត្ត ដោយគុណដ៏ប្រសើរ (ទំនុកដំកើង១១៦:៦-៧)។**

ព្រះអង្គសន្យាក្នុងព្រះបន្ទូលព្រះអង្គថា បើយើងអំពាវនាវរកព្រះអង្គ ព្រះអង្គពិតជាឆ្លើយតបចំពោះយើង ព្រមទាំងអោយព្រលឹងរបស់យើងបានសម្រាកផង។

**គឺខ្ញុំនឹងទទួលយកពែងនៃសេចក្តីសង្គ្រោះ ហើយនឹងអំពាវនាវដល់ព្រះនាមព្រះយេហូវ៉ា (ទំនុកដំកើង១១៦:១៣)។**

ពែងនេះ គឺជាពែងនៃសេចក្តីសង្គ្រោះ។ ព្រះអម្ចាស់យេស៊ូវត្រូវទទួលពែងទុក្ខលំបាកជំនួសយើង ដើម្បីផ្តល់សេចក្តីសង្គ្រោះដល់អស់អ្នកណាដែលជឿដល់ទ្រង់។

## ទ្រង់សម្តែងភាពបរិសុទ្ធរបស់ទ្រង់

ព្រះជាម្ចាស់ទ្រង់មានភាពបរិសុទ្ធខ្លាំងណាស់ បានជាព្រះអង្គអាចជួយសង្គ្រោះដល់រូបយើងបាន។

**ការស្លាប់របស់ពួកអ្នកបរិសុទ្ធនៃព្រះយេហូវ៉ា ជាការវិសេសដល់ព្រះនេត្រទ្រង់ (ទំនុកដំកើង១១៦:១៥)។**

សេចក្តីសុគតរបស់ព្រះអម្ចាស់យេស៊ូវ មានតម្លៃចំពោះព្រះនេត្រព្រះជាម្ចាស់។ ចំណែកឯសេចក្តីស្លាប់របស់អ្នកជឿដល់ព្រះអម្ចាស់ មានតម្លៃយ៉ាងខ្លាំងនៅចំពោះព្រះនេត្រព្រះអង្គដែរ។

**[១៦]ឱព្រះយេហូវ៉ាអើយ ទូលបង្គំជាទាសារបស់ទ្រង់ពិត គឺជាទាសារបស់ទ្រង់ ហើយជាកូននៃទាសីរបស់ទ្រង់ តែទ្រង់បានស្រាយចំណងរបស់ទូលបង្គំចេញហើយ [១៧]ទូលបង្គំនឹងថ្វាយដង្វាយជាសេចក្តីអរព្រះគុណ ដល់ព្រះយេហូវ៉ា ហើយនឹងអំពាវនាវដល់ព្រះនាមទ្រង់ (ទំនុកដំកើង១១៦:១៦-១៧)។**

ព្រះជាម្ចាស់មានព្រះហឫទ័យសប្បុរស ចំពោះមនុស្សលោកខ្លាំងណាស់។ តើព្រះអង្គចង់បានអ្វីពីមនុស្សលោក? ការដែលព្រះអម្ចាស់ចង់បានពីមនុស្សលោក និងមាបនវត្ថុទាំងអស់ ដែលព្រះអម្ចាស់បង្កើតមក គឺការថ្វាយពាក្យអរព្រះគុណ។ គម្ពីរហេព្រើរ១៣:១៥ សម្តែងពីសេចក្តីនេះដែរថា "ដូច្នេះ ត្រូវឱ្យយើងរាល់គ្នាថ្វាយពាក្យសរសើរដោយសារទ្រង់ ទុកជាគ្រឿងបូជាដល់ព្រះជានិច្ច គឺជាផលនៃបបូរមាត់ ដែលថ្លែងប្រាប់ពីព្រះនាមទ្រង់"។ សូមលោកអ្នកបងប្អូនកុំភ្លេច នឹងថ្វាយពាក្យអរព្រះគុណដល់ព្រះជាម្ចាស់រៀងរាល់ដង្ហើមចេញចូល ពេលយើងរស់នៅលើផែនដីនេះ។

យើងស្លេះការសិក្សាគម្ពីរទំនុកដំកើងត្រឹមណោះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"